ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៥
ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១

សំណុំរឿងស៊ើបសួរលេខ ២៨៣ ម.ខ
ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១

សំណុំរឿងជំនុំជម្រះលេខ ៦៦
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

សាលក្រមព្រហ្មទណ្ឌ
លេខ ១០៣/១៥ ក្រខ "ច"
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

# សាលក្រមព្រហ្មទណ្ឌ
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ
នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៣ រសៀល
ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងជំនុំជម្រះលេខ ៦៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ ដែលត្រូវបានបញ្ជូនមកតុលាការជំនុំជម្រះ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦៥២៩ ត៣/២១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ។

## ១. ភាគី និងវត្ថុចាប់យក

### ១.១. ជនជាប់ចោទ

ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ២៩ឆ្នាំ កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅ[redacted] ខេត្តព្រះសីហនុ និងមានអាសយដ្ឋានមិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted]ស្រីល័ក្ខ មានកូនចំនួន ១ នាក់ ឪពុកឈ្មោះ [redacted]ចន្ទា (រស់) ម្តាយឈ្មោះ [redacted]លីហួយ (រស់) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ជានីតិជន ។



Scanned with CamScanner

ជនជាប់ចោទរូបនេះត្រូវបានឃុំខ្លួន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤១៥ តព/២១ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១ ។

ជននេះមានលោកមេធាវី [redacted] ជាមេធាវីការពារ ។

ជននេះត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចម្តុំLV ស្ថិតនៅក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៩ និងថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

### ១.២. ជនរងគ្រោះ

ឈ្មោះ [redacted] វ៉េង ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ជនរងគ្រោះពុំបានប្ដឹងទាមទារសំណងនោះទេ ។

### ១.៣. វត្ថុចាប់យក

វត្ថុចាប់យក ដែលបានដកហូតពីជនជាប់ចោទខាងលើ រួមមាន ៖

- ម៉ូតូចំនួន ១ គ្រឿងម៉ាក ZOOMER-X ពណ៌ទឹកក្រូច សេរីឆ្នាំ២០១៧ ពាក់ផ្លាកលេខ1DQ-7291
- រណារអារដែកចំនួន ១ គ្រឿង
- ដែកកាប់ចំនួន ១ មានដងជ័រ ពណ៌ក្រហមលាយលឿង
- ទួលល្វីសចំនួន ១ មានដងជ័រពណ៌លឿង ។

## ២. អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] **សុខហេង** បានធ្វើសកម្មភាពយករណារអារដែកបង្កួច រួចចូលទៅក្នុងផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] វ៉េង នៅម្តុំអិលវី ស្ថិតនៅក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ក្នុងអំពើលួចនាថ្ងៃទី២៩ នេះ ឈ្មោះ [redacted] **សុខហេង** លួចបានពូកចំនួន ២ ដោយឈ្មោះ [redacted] **សុខហេង** បានប្រើម៉ូតូមកដឹកពូកទាំងពីរនេះយកទៅលក់នៅដេប៉ូលក់ និងទិញសម្ភារៈផ្ទះ នៅផ្លូវសេតេលក់បានប្រាក់ចំនួន ៨០ (ប៉ែតសិប) ដុល្លាអាមេរិក ។ លុះដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] **សុខហេង** បានធ្វើសកម្មភាពលួចនេះម្តងទៀតនៅទីតាំងចំណុចខាងលើដដែល ហើយក៏ត្រូវបានជនរងគ្រោះឈ្មោះ [redacted] វ៉េង មកទាន់ និងចាប់ឈ្មោះ [redacted] **សុខហេង** ឱ្យសមត្ថកិច្ចតែម្តង ។



Scanned with CamScanner

## ៣. ដំណើរការនៃកិច្ចពិភាក្សាដេញដោល

### ៣.១. បញ្ហាកិច្ចនីតិវិធី

នៅក្នុងកិច្ចពិភាក្សាដេញដោល បុគ្គលដែលមានវត្តមាន រួមមាន ជនជាប់ចោទឈ្មោះ [redacted] សុខហេង និងលោកមេធាវី [redacted] ដែលការពារឱ្យជនជាប់ចោទ មានវត្តមាន ។ មេធាវី និងតំណាងអយ្យការមិនមានការជំទាស់ទៅនឹងបញ្ហានីតិវិធីណាមួយទេ និងបានស្នើសុំតុលាការបន្តកិច្ចពិភាក្សាដេញដោលទៅតាមនីតិវិធីច្បាប់ ។ តុលាការសម្រេចបន្តដំណើរការនៃកិច្ចពិភាក្សាដេញដោល ។

### ៣.២. ចម្លើយ ឬអំណានចម្លើយរបស់ភាគី និងកិច្ចផ្សេងទៀតក្នុងការពិភាក្សាដេញដោល

ជនជាប់ចោទឈ្មោះ [redacted] **សុខហេង** បានឆ្លើយថា ៖ ខ្លួនបានចូលទៅលួចពូករបស់គេនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ ដោយបានផ្លោះរបងចូល ។ ខ្លួនមិនបានយករណារអារចម្រឹងបង្អួចនោះទេ ។ ខ្លួនលួចបានពូកចំនួន ២ ហើយយកទៅលក់ ដោយពូកមួយលក់បានចំនួន ៨០ ដុល្លារអាមេរិក ។

លោកស្រីក្រឡាបញ្ជី [redacted] បានអានសេចក្ដីសន្និដ្ឋានដែលមាននៅក្នុងរបាយការណ៍លេខ ១២៥ រ.ប.ក/២១ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ និងកំណត់ហេតុស្ដាប់ចម្លើយរបស់ជនរងគ្រោះនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ។

### ៣.៣. សេចក្ដីសន្និដ្ឋាន និងការកត់សម្គាល់របស់ភាគី ក្រោយពីកិច្ចពិភាក្សាដេញដោល

លោកព្រះរាជអាជ្ញារង [redacted]ជាប បានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ៖ ក្រោយពីស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងអំណានចម្លើយរបស់ជនរងគ្រោះ ព្រមទាំងពិនិត្យកស្ដុតាងក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចអង្គហេតុដែលប្ដឹងមកតុលាការជំនុំជម្រះមែន ហើយអំពើនេះជាបទ **លួចមានស្ថានទម្ងន់ទោស** បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា **៣៥៣** និង **៣៥៧** នៃក្រមព្រហ្មទណ្ឌ ហេតុនេះ ស្នើសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

មេធាវី[redacted] បានធ្វើការកត់សម្គាល់ថា ៖ កូនក្ដីខ្លួនបានសារភាពពីអំពើរបស់គាត់ ។ ការដែលកូនក្ដីខ្លួនធ្វើអំពើលួចបែបនេះដោយសារតែជីវភាពទីទ័លក្រ មានគ្រួសារ និងកូនតូចៗត្រូវការគាត់ចិញ្ចឹមបីបាច់ថែរក្សា ។ ណាមួយកូនក្ដីខ្លួនមានកម្រិតវប្បធម៌យល់ដឹងពុំបានជ្រៅជ្រះ ជាហេតុធ្វើឱ្យការពិចារណាពុំបានវែងឆ្ងាយ ។ ហេតុដូច្នេះ ខ្លួនស្នើសុំឱ្យតុលាការផ្ដល់ស្ថានសម្រាលណាមួយដល់កូនក្ដីខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] **សុខហេង** បានផ្ដល់សេចក្ដីកត់សម្គាល់ថា ៖ ខ្ញុំសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ខ្លួនលែងហ៊ានប្រព្រឹត្តអំពើបែបនេះទៀតហើយ ។

## ៤. សំអាងហេតុ

### ៤.១. បញ្ហាពិរុទ្ធភាព

(១). តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៦៥២៩** ត.៣/២១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សុខហេង** មកតុលាការដើម្បីធ្វើការជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចម្ដុំ LV នៅក្រុមទី១៥ ភូមិ៣ សង្កាត់លេខ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និង **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

(២). នៅពេលសវនាការ ជនជាប់ចោទបានឆ្លើយថា " នៅថ្ងៃកើតហេតុ ខ្លួនបានចូលទៅលួចពូករបស់ជនរងគ្រោះមែន តែខ្លួនផ្លោះរបងចូល ហើយមិនបានយករណារមកអារចម្រឹងបង្អួចនោះទេ ។" បើផ្អែកតាមចម្លើយនេះ តុលាការពិនិត្យឃើញថា ជនជាប់ចោទបានសារភាពអំពីនៃការចូលលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ប៉ុន្តែអ្វីជាបញ្ហាចោទនោះគឺថា តើជនជាប់ចោទបានប្រើរណារអារចម្រឹងបង្អួចដើម្បីចូលលួចដែរ ឬទេ ?

(៣). បើផ្អែកតាមភស្តុតាងដែលមានក្នុងសំណុំរឿងនេះ ដូចជាចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាលសមត្ថកិច្ច ដែលថាឆ្លើយ "ខ្លួនបានយករណារអារដែកបង្អួចកញ្ចក់ រួចហើយចូលលួចនោះ" ជាមួយនឹងវត្ថុតាងជា "រណារ" ដែលសមត្ថកិច្ចបានដកហូតនោះ តុលាការយល់ឃើញថាចម្លើយរបស់ជនជាប់ចោទនាពេលសវនាការខាងលើនេះ គឺជាចម្លើយដោះសារតែប៉ុណ្ណោះ ។ ភស្តុតាងបង្ហាញក្នុងចំណុចបង្កើតជាហេតុផលគ្រប់គ្រាន់អាចបង្ហាញថា ជនជាប់ចោទពិតជាបានប្រើរណារអារកាត់ដែក ឬចម្រឹងបង្អួចផ្ទះរបស់ជនរងគ្រោះ ដើម្បីចូលទៅលួចទ្រព្យសម្បត្តិជនរងគ្រោះមែន ។

(៣). ជនជាប់ចោទពិតជាបានដឹងថា ការយកទ្រព្យសម្បត្តិរបស់អ្នកដទៃគឺជាអំពើល្មើសច្បាប់ ប៉ុន្តែជននេះនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិត ។ អំពើរបស់ជនជាប់ចោទក៏បង្កជាផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម ដែលច្បាប់បានកំណត់ថាជាបទ **លួចមានស្ថានទម្ងន់ទោស** បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និង **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

(៤). ជារួម តុលាការយល់ឃើញ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ **ចាយ សុខហេង** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចម្ដុំ LV នៅក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** កថាខណ្ឌទី **២** នៃក្រមព្រហ្មទណ្ឌ ដែលតុលាការគប្បីពិចារណាអំពីការប្រកាសផ្តន្ទាទោសលើជនជាប់ចោទទៅតាមបញ្ញត្តិច្បាប់ និងវត្ថុចាប់យកផងដែរ ។

៤.២. ការផ្តន្ទាទោស និងវត្ថុចាប់យក

(១). តំណាងអយ្យការបានស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ដោយមិនបានបញ្ជាក់អំពីកម្រិតទោសដាក់ពន្ធនាគារទេ ។ ជនជាប់ចោទ និងមេធាវីការពារឱ្យជនជាប់ចោទ បានសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ព្រោះជនជាប់ចោទមានជីវភាពក្រីក្រ មានគ្រួសារត្រូវចិញ្ចឹម និងពុំមានចំណេះជ្រៅជ្រះ ។

(២). តុលាការពិនិត្យឃើញថា អំពើរបស់ជនជាប់ចោទពិតជាបានបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃផងដែរ ប៉ុន្តែព្យសនកម្មក្នុងរឿងនេះគឺមិនមានលក្ខណៈធ្ងន់ធ្ងរប៉ុន្មាននោះទេ ។ បន្ថែមពីនេះ បានសារភាពទទួលស្គាល់កំហុសពីអំពើខ្លះរបស់ខ្លួន ព្រមទាំងបង្ហាញការស្តាយក្រោយ បន្ទាប់ពីទទួលរងការជាប់ពន្ធនាគារមួយរយៈ ។ មួយវិញទៀត ជនជាប់ចោទក៏ពុំមានប្រវត្តិនៃការផ្តន្ទាទោសពីមុនមកដែរ ។ ដោយពិចារណាអំពីស្ថានភាពទាំងនេះ ជាមួយនឹងមូលហេតុនៃការស្នើសុំរបស់ជនជាប់ចោទ ក៏ដូចជាមេធាវីការពារឱ្យជនជាប់ចោទនោះ តុលាការយល់ឃើញថា ការផ្តន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទឈ្មោះ [redacted] សុខហេង ចំនួន ៣ (បី) **ឆ្នាំ** ដោយឱ្យជនជាប់ចោទអនុវត្តទោសពន្ធនាគារ ចំនួន **១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ** គឺធួនល្មមនឹងអំពើដែលជនជាប់ចោទបានប្រព្រឹត្ត និងព្យសនកម្មដែលបានកើតឡើង និងបង្ការកុំឱ្យហ៊ានប្រព្រឹត្តអំពើបែបនេះនៅថ្ងៃក្រោយទៀត ក៏ជាការផ្តល់ឱកាសឱ្យជនជាប់ចោទអាចកែប្រែខ្លួនដោយខ្លួននៅក្រៅពន្ធនាគារ ។

(៣). វត្ថុចាប់យកមាន ម៉ូតូចំនួន ១ គ្រឿងម៉ាក ZOOMER-X ពណ៌ទឹកក្រូចសេរីឆ្នាំ២០១៧ ពាក់ផ្លាកលេខ1DQ-7291 , រណារអារដែកចំនួន ១ គ្រឿង , ដែកកាប់ចំនួន ១ មានដងជ័រ ពណ៌ក្រហមលាយលឿង និងទួលល្វីសចំនួន ១ មានដងជ័រពណ៌លឿង គប្បីតុលាការសម្រេចរឹបអូសព្រោះ ជាឧបករណ៍ដែលជនជាប់ចោទប្រើប្រាស់សម្រាប់ប្រព្រឹត្តិបទល្មើស ។

## ៥. សេចក្តីសម្រេច

(១). ផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **សុខហេង** ភេទប្រុស កើតឆ្នាំ ១៩៩៣ (អាយុ២៨ឆ្នាំ) ចំនួន **៣ (បី) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចម៉ុំ LV នៅក្រុមទី១៥ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និង មាត្រា **៣៥៧** កថាខណ្ឌទី **២** នៃក្រមព្រហ្មទណ្ឌ ។ ចំពោះទោសដាក់ពន្ធនាគារចំនួន **៣ (បី) ឆ្នាំ** នេះ ជនជាប់ចោទត្រូវអនុវត្តទោស ចំនួន **១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ** ហើយទោសដែលនៅសល់ត្រូវព្យួរ ។



Scanned with CamScanner

(២). វិបអូសវត្ថុចាប់យក ដូចខាងក្រោម ៖

- ម៉ូតូចំនួន ១ គ្រឿងម៉ាក ZOOMER-X ពណ៌ទឹកក្រូចសេរីឆ្នាំ២០១៧ ពាក់ស្លាកលេខ1DQ-7291
- រណារអារដែកចំនួន ១ គ្រឿង
- ដែកកាប់ចំនួន ១ មានដងជ័រ ពណ៌ក្រហមលាយលឿង
- ទួលលីសចំនួន ១ មានដងជ័រពណ៌លឿង ។

សាលក្រមនេះត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២២ ។ សាលក្រមនេះជាសាលក្រមចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខហេង ។ ក្នុងករណីប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ១ (មួយ) ខែ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តព្រះសីហនុ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ បានឃើញ

**ក្រឡាបញ្ជី** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted]